ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៦៣.០២២.៩៩០.ស.ផ.ណ.

ថ្ងៃ សុក្រ ៩កើត ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែធ្នូ ឆ្នាំ២០២២

# សេចក្តីជូនដំណឹង ស្តីពី
# សន្និសីទថ្នាក់ទេសាភិបាលស៊ាសិនលើកទី ៥៨ និង
# សិក្ខាសាលាជាន់ខ្ពស់ SEACEN-IMF-STI
# និងកិច្ចប្រជុំក្រុមប្រឹក្សានៃទេសាភិបាលស៊ាសិនលើកទី ៤២

ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាប្រធានប្តូរវេននៃមជ្ឈមណ្ឌលស្រាវជ្រាវនិងបណ្តុះបណ្តាលធនាគារកណ្តាលអាស៊ីអាគ្នេយ៍ (ដែលហៅកាត់ថា ស៊ាសិន) សម្រាប់ឆ្នាំ២០២៣ នឹងរៀបចំសន្និសីទថ្នាក់ទេសាភិបាលស៊ាសិនលើកទី៥៨ និងសិក្ខាសាលាជាន់ខ្ពស់ SEACEN-IMF-STI ព្រមទាំងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃទេសាភិបាលស៊ាសិន លើកទី៤២ នៅថ្ងៃទី៤-៦ ខែធ្នូ ឆ្នាំ២០២២ នៅខេត្តសៀមរាប។

សន្និសីទនិងសិក្ខាសាលាជាន់ខ្ពស់នេះត្រូវបានរៀបចំជាលក្ខណៈអ៊ីប្រ៊ីដ ដោយមានការចូលរួមផ្ទាល់ និងតាមប្រព័ន្ធអនឡាញ ដោយទេសាភិបាលធនាគារកណ្តាល និងនាយកគ្រប់គ្រងអាជ្ញាធររូបិយវត្ថុដែលជាសមាជិកស៊ាសិនចំនួន ១៩ ប្រទេសនៅក្នុងតំបន់ ព្រមទាំងមានការចូលរួមជាកិត្តិយសពី លោកជំទាវ Christine Lagarde ប្រធានធនាគារកណ្តាលអឺរ៉ុប (ECB) តំណាងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Harvard និងស្ថាប័នអន្តរជាតិមួយចំនួនទៀត។ សន្និសីទនាឆ្នាំនេះត្រូវបានរៀបចំឡើងក្រោមមូលបទៈ "បញ្ហាប្រឈមនៃគោលនយោបាយបច្ចុប្បន្នៈ បរិបទសេដ្ឋកិច្ចសកលនិងអាស៊ី បញ្ហាប្រឈមនៃការផ្លាស់ប្តូរ និងការពង្រីកការផ្តល់ហិរញ្ញប្បទានអាកាសធាតុ"។

ទន្ទឹមនេះ ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាប្រធានប្តូរវេននឹងដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សានៃទេសាភិបាលស៊ាសិនលើកទី៤២ ដើម្បីពិនិត្យនិងពិភាក្សាលើវឌ្ឍនភាពការងាររបស់មជ្ឈមណ្ឌលស៊ាសិន ដែលសម្រេចបានក្នុងរយៈពេល ១ឆ្នាំកន្លងទៅនេះ និងកំណត់ទិសដៅការងារចម្បងៗ ដែលនឹងគាំទ្រដល់មុខងារ-ភារកិច្ចរបស់មជ្ឈមណ្ឌលស៊ាសិន ដែលក្នុងនោះរួមមានៈ ការបណ្តុះបណ្តាលជំនាញការងារធនាគារកណ្តាល ភាពជាអ្នកដឹកនាំ ការពង្រឹងការស្រាវជ្រាវក្នុងតំបន់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងប្រទេសជាសមាជិក។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

នាឱកាសនោះដែរ គណៈប្រតិភូដែលចូលរួមសន្និសីទនិងកិច្ចប្រជុំខាងលើ ក៏នឹងអញ្ជើញទស្សនាស្វែងយល់ពីសក្តានុពលទេសចរណ៍ប្រវត្តិសាស្ត្រកម្ពុជា ក៏ដូចជាវប្បធម៌ និងប្រពៃណីខ្មែរដែលមានលើទឹកដីនៃខេត្តសៀមរាបផងដែរ។

គួររំលេចថា មជ្ឈមណ្ឌលស៊ាសិនត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៨២ ដោយមានបេសកកម្មចម្បងផ្តោតលើការពង្រឹងសមត្ថភាពជំនាញរបស់មន្ត្រី-បុគ្គលិកធនាគារកណ្តាល និងអាជ្ញាធររូបិយវត្ថុជាសមាជិក តាមរយៈការបណ្តុះបណ្តាលនិងស្រាវជ្រាវ។ បច្ចុប្បន្ន មជ្ឈមណ្ឌលស៊ាសិន មានសមាជិកដែលជាធនាគារកណ្តាលនិងអាជ្ញាធររូបិយវត្ថុ ចំនួន១៩ ដូចជា៖ ព្រុយណេ កម្ពុជា ចិន ឥណ្ឌា ឥណ្ឌូណេស៊ី ហុងកុង កូរ៉េខាងត្បូង ឡាវ ម៉ាឡេស៊ី ម៉ុងហ្គោលី មីយ៉ាន់ម៉ា នេប៉ាល់ ប៉ាពូអាស៊ីនូវែល-ហ្គីណេ ហ្វីលីពីន សិង្ហបុរី ស្រីលង្កា តៃវ៉ាន់ ថៃ និងវៀតណាម។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៨០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh

**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.org.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA